ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៨៤ ព.ណអ.ក.បប.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការដោះស្រាយតាមរយៈការចរចា ចំពោះបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ៩៥ សសរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ កំណត់អំពីនីតិវិធីនៃការដោះស្រាយតាមរយៈការចរចា ចំពោះបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីការពារសិទ្ធិ និងអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់ និងអនុវត្តដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដោះស្រាយតាមរយៈការចរចា ដែលធ្វើឡើងដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត របស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» និង គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.» ចំពោះបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៣ ._**

វាក្យស័ព្ទសំខាន់ៗមួយចំនួននៃប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **បណ្តឹង** សំដៅដល់ការបង្ហាញអំពីការមិនពេញចិត្តចំពោះទំនិញ ឬសេវាណាមួយ ពីអ្នកប្រើប្រាស់ សមាគមអ្នកប្រើប្រាស់ អង្គការ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។

២. **សេចក្តីសម្រេច** សំដៅដល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

៣. **បុគ្គលស្ថិតក្រោមការស៊ើបអង្កេត** សំដៅដល់បុគ្គលទាំងឡាយណាដែលសង្ស័យថាបានបំពានច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៤. **មន្ត្រីស៊ើបអង្កេត** សំដៅដល់មន្ត្រីនៃអគ្គនាយកដ្ឋាន ក.ប.ប. ដែលត្រូវបានចាត់ឱ្យស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៥. **គ.ជ.ក.ប.** សំដៅដល់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

៦. **ការដោះស្រាយតាមរយៈការចរចារ** សំដៅដល់ការដោះស្រាយបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់តាមរយៈការចរចាររវាងបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេត និង គ.ជ.ក.ប.។

៧. **ករណីព្រហ្មទណ្ឌ** សំដៅដល់បទល្មើសក្រោមវិសាលភាពច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលស្ថានទម្ងន់ទោសឈានទៅដល់ការប៉ះពាល់សុខភាព សុវត្ថិភាព ពិការភាព ឬមរណភាព។

៨. **ព័ត៌មានមានលក្ខណៈជាការសម្ងាត់** សំដៅដល់ព័ត៌មានទាំងឡាយដែលការបែកធ្លាយអាចធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ការធ្វើធុរកិច្ចរបស់បុគ្គលណាមួយ។

**ប្រការ៤ ._**

អនុញ្ញាតឱ្យមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ទទួលពាក្យស្នើសុំការដោះស្រាយបទល្មើស តាមរយៈការចរចា ព្រមទាំងត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើពាក្យស្នើសុំនោះ។

**ប្រការ៥ ._**

បុគ្គលស្ថិតក្រោមការស៊ើបអង្កេត អាចដាក់ពាក្យស្នើសុំការដោះស្រាយតាមរយៈការចរចា ទៅមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. មុនពេលមន្ត្រីស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានចំពោះការបំពាន លើកលែងតែបទល្មើសនោះជាការបំពានបទប្បញ្ញត្តិនានានៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ជាថ្មីម្តងទៀត ក្នុងអំឡុងពេល៣ (បី)ឆ្នាំ ឬពាក់ព័ន្ធដល់ករណីព្រហ្មទណ្ឌ។

**ប្រការ៦ ._**

ពាក្យស្នើសុំការដោះស្រាយបទល្មើសតាមរយៈការចរចា ត្រូវតែស្ថិតក្នុងទម្រង់ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ឬត្រូវបានកំណត់ផ្សេងទៀតដោយ គ.ជ.ក.ប. និងត្រូវចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬអ្នកតំណាងស្របច្បាប់។

**ប្រការ៧ ..**

ក្នុងករណីមន្ត្រីស៊ើបអង្កេត មិនយល់ស្របក្នុងការចាប់ផ្តើមនីតិវិធីដោះស្រាយបទល្មើសតាមរយៈការចរចាជាមួយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដោយបញ្ជាក់នូវហេតុផលសមស្រប និងមានការឯកភាពពី គ.ជ.ក.ប.។

ក្នុងករណីមន្ត្រីស៊ើបអង្កេត យល់ស្របក្នុងការចាប់ផ្តើមនីតិវិធីដោះស្រាយបទល្មើសតាមរយៈការចរចា ជាមួយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីនីតិវិធីនៃការអនុវត្តបន្ត និងការពិន័យអន្តរការណ៍ដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងមានការឯកភាពពី គ.ជ.ក.ប.។

**ប្រការ៨ ..**

ក្នុងដំណាក់កាលដោះស្រាយតាមរយៈការចរចា បុគ្គលស្ថិតក្រោមការស៊ើបអង្កេតត្រូវផ្តល់ព័ត៌មានដែលស្នើឡើងដោយមន្ត្រីស៊ើបអង្កេតជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់អំពីភាពត្រឹមត្រូវ និងភាពពេញលេញនៃព័ត៌មាន ព្រមទាំងចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬតំណាងស្របច្បាប់។

មន្ត្រីស៊ើបអង្កេតអាចធ្វើការពិភាក្សាលើដំណោះស្រាយសមស្របណាមួយ ជាមួយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬស្នើសុំធាតុចូលបន្ថែមពីក្រសួង ស្ថាប័ន បញ្ញត្តិករមានសមត្ថកិច្ច សមាគមអ្នកប្រើប្រាស់ ឬអង្គការនានា ដើម្បីធ្វើការវាយតម្លៃលើភាពសមស្រប និងប្រសិទ្ធភាពនៃដំណោះស្រាយមុននឹងបញ្ជូនទៅ គ.ជ.ក.ប.។

គ.ជ.ក.ប. ត្រូវចេញសេចក្តីសម្រេចលើដំណោះស្រាយខាងលើ ក្នុងករណីដែលលក្ខខណ្ឌដូចបានកំណត់ក្នុងដំណោះស្រាយនោះមានលក្ខណៈគ្រប់គ្រាន់។

**ប្រការ៩ ..**

កំណត់ហេតុនៃការដោះស្រាយបទល្មើសតាមរយៈការចរចារវាងមន្ត្រីស៊ើបអង្កេត និងបុគ្គលស្ថិតក្រោមការស៊ើបអង្កេតត្រូវបញ្ជាក់អំពី៖

- ទំហំ និងលក្ខខណ្ឌនៃការទូទាត់សំណងជូនដល់អ្នកប្រើប្រាស់ ដែលទទួលរងការប៉ះពាល់ដោយការបំពានច្បាប់ ព្រមទាំងលក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗ ដែលត្រូវបំពេញដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត
- សិទ្ធិរបស់មន្ត្រីស៊ើបអង្កេតក្នុងការពិនិត្យ និងតាមដានការអនុវត្តលក្ខខណ្ឌ និងកាតព្វកិច្ចខាងលើក្នុងអំឡុងពេលអនុវត្តដំណោះស្រាយនោះ។

**ប្រការ១០ ..**

ការដោះស្រាយបទល្មើសតាមរយៈការចរចា ត្រូវមោឃភាព ប្រសិនបើ៖

- បុគ្គលស្ថិតក្រោមការស៊ើបអង្កេត ផ្តល់ព័ត៌មានមិនពិត ឬមានលក្ខណៈបោកបញ្ឆោត
- បុគ្គលស្ថិតក្រោមការស៊ើបអង្កេត កំពុងស្ថិតក្នុងការពិចារណារបស់ គ.ជ.ក.ប. ក្នុងការសម្រេចថា បានបំពានបទប្បញ្ញត្តិណាមួយផ្សេងទៀតក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ក្នុងអំឡុងពេល ៣(បី)ឆ្នាំ ឬ
- ករណីដែលកំពុងស៊ើបអង្កេតនេះ អាចឈានទៅដល់ករណីព្រហ្មទណ្ឌ។

ការដោះស្រាយមានសុពលភាព មានអានុភាពអនុវត្តបាន និងអាចបញ្ចប់ដំណើរការស៊ើបអង្កេតបាន លុះត្រាតែការដោះស្រាយនោះ ត្រូវបានឯកភាពដោយសេចក្តីសម្រេចរបស់ គ.ជ.ក.ប.។

ការដោះស្រាយត្រូវអស់សុពលភាពនៅពេលដែលកាតព្វកិច្ច ឬលក្ខខណ្ឌដែលមានចែងក្នុងកំណត់ហេតុនៃការដោះស្រាយនោះ ត្រូវបានបំពេញ ឬមានការកំណត់ផ្សេងពីនេះ ដូចមានចែងក្នុងកំណត់ហេតុនេះ។

**ប្រការ១១ ៖**

កំណត់ហេតុនៃការដោះស្រាយបទល្មើសតាមរយៈការចរចា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងមន្ត្រីស៊ើបអង្កេត ដោយមួយច្បាប់ត្រូវប្រគល់ជូនបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងពីរច្បាប់ទៀតត្រូវរក្សាទុក ដោយមន្ត្រីស៊ើបអង្កេត និង គ.ជ.ក.ប.។

មន្ត្រីស៊ើបអង្កេតត្រូវតម្កល់កំណត់ហេតុនៃការដោះស្រាយទាំងអស់ រួមទាំងព័ត៌មាន លក្ខខណ្ឌនានាដែលមានចែងក្នុងកំណត់ហេតុ និងបច្ចុប្បន្នភាពនៃការដោះស្រាយ។ កំណត់ហេតុនៃការដោះស្រាយអាចផ្ដល់ជូនដល់សាធារណជនតាមការសម្រេចរបស់ គ.ជ.ក.ប.។

**ប្រការ១២ ៖**

គ.ជ.ក.ប. អាចផ្សព្វផ្សាយជាសាធារណៈនូវរាល់ព័ត៌មានមិនមានលក្ខណៈជាការសម្ងាត់ ពាក់ព័ន្ធនឹងការដោះស្រាយដោយរួមបញ្ចូលនូវសេចក្ដីពិពណ៌នាអំពីការបំពានដែលកើតឡើងក្រោមច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងលក្ខខណ្ឌនានាដែលមានចែងនៅក្នុងកំណត់ហេតុនៃការដោះស្រាយនោះ។

**ប្រការ១៣ ៖**

មន្ត្រីស៊ើបអង្កេតត្រូវពិនិត្យ និងតាមដានអនុលោមភាព ក្នុងការបំពេញលក្ខខណ្ឌនៃការដោះស្រាយបទល្មើសតាមរយៈការចរចា នៅពេលដែលដំណោះស្រាយត្រូវបានឯកភាពដោយ គ.ជ.ក.ប.។

ក្នុងអំឡុងពេលអនុវត្តដំណោះស្រាយ មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំព័ត៌មានបន្ថែម អង្កេត ឬស្រាវជ្រាវ ចំពោះបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើសកម្មភាពនានាដែលស្ថិតនៅក្រោមលក្ខខណ្ឌនៃការដោះស្រាយ។

**ប្រការ១៤ ៖**

ការតវ៉ា ឬការបញ្ចប់ការដោះស្រាយ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១. បុគ្គលដែលទទួលរងផលប៉ះពាល់ពីការដោះស្រាយ អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមក គ.ជ.ក.ប. ឱ្យធ្វើការពិនិត្យឡើងវិញនូវកំណត់ហេតុនៃការដោះស្រាយ ក្នុងអំឡុងពេលការដោះស្រាយនោះ នៅមានសុពលភាព។

២. គ.ជ.ក.ប. អាចសម្រេចថាមិនទទួលយកការតវ៉ា ដោយផ្អែកលើហេតុផលសមស្របណាមួយ និងត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរជូនទៅបុគ្គលតវ៉ា ដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចមិនទទួលយកការតវ៉ានោះ។

៣. គ.ជ.ក.ប. អាចកែសម្រួល ឬបញ្ចប់ការដោះស្រាយជារួម ឬដោយផ្នែក ប្រសិនបើការដោះស្រាយនោះមិនមានប្រសិទ្ធភាព ឬមិនចាំបាច់ក្នុងការរារាំងការបំពានលើបញ្ញត្តិណាមួយក្រោមច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់។

៤. មុននឹងធ្វើការសម្រេចដូចមានចែងក្នុងកថាខណ្ឌទី២ និងទី៣ ខាងលើ គ.ជ.ក.ប. អាចធ្វើការសាកសួរជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ពីបុគ្គលតវ៉ា មន្ត្រីស៊ើបអង្កេត និងភាគីពាក់ព័ន្ធរួមមានតំណាងក្រសួង ស្ថាប័ន សាធារណជន បញ្ញត្តិករមានសមត្ថកិច្ច តតីយជន ឬសមាគមអ្នកប្រើប្រាស់។

៥. សេចក្ដីសម្រេចក្នុងការកែសម្រួល ឬបញ្ចប់ការដោះស្រាយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានអំណះអំណាងច្បាស់លាស់ ដោយមួយច្បាប់ជូនទៅបុគ្គលតវ៉ា និងពីរច្បាប់ទៀតត្រូវរក្សាទុកដោយមន្ត្រីស៊ើបអង្កេត និង គ.ជ.ក.ប.។

៦. សេចក្ដីសម្រេចរបស់ គ.ជ.ក.ប. លើការស្នើសុំកែសម្រួល ឬបញ្ចប់ការដោះស្រាយ អាចត្រូវបានប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនោះ។

**ប្រការ១៥ ._**

ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មិនអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងសេចក្តីសម្រេចនៃការដោះស្រាយបទល្មើសតាមរយៈការចរចា គ.ជ.ក.ប. អាចស្នើសុំជំនួយពីស្ថាប័នតុលាការមានសមត្ថកិច្ចដើម្បីអនុវត្ត។

**ប្រការ១៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧ ._**

សមាសភាពគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំដោះស្រាយតាមការចរចា

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.................................ភេទ.......អាយុ........ឆ្នាំ ជនជាតិ..............សញ្ជាតិ..........
មុខរបរ...........................................................ទីលំនៅពិតប្រាកដផ្ទះលេខ.......................ផ្លូវ................
សង្កាត់/ឃុំ...................................ខណ្ឌ/ស្រុក/ក្រុង........................ខេត្ត/រាជធានី..............................

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

**កម្មវត្ថុ** ៖ សំណើសុំដោះស្រាយតាមការចរចាលើសំណុំរឿងលេខ.................ចុះថ្ងៃទី.......................

**ជូនភ្ជាប់** ៖ ..............................................................................................................................
..............................................................................................................................
..............................................................................................................................

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំស្នើសុំដោះស្រាយតាមការចរចាលើ
សំណុំរឿង.............................................................................................................................

មូលហេតុ៖.............................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យនិងសម្រេចអនុញ្ញាតឱ្យខ្ញុំបាទ-នាងខ្ញុំ ចូលរួមក្នុងការដោះស្រាយតាមរយៈការចរចាចំពោះសំណុំរឿងខាងលើដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥......

ធ្វើនៅ................................... ថ្ងៃទី.........ខែ.........ឆ្នាំ២០........

**ស្នាមមេដៃស្ដាំ**

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

សុំណុំរឿងលេខ:................................................

ចុះថ្ងៃទី..........................................................

សេចក្តីសម្រេចលេខ:.......................................ថ្ងៃទី.......................................................

## សេចក្តីសម្រេច
## លើពាក្យស្នើសុំដោះស្រាយតាមរយៈការចរចា

យោង ៖ - ពាក្យស្នើសុំដោះស្រាយតាមរយៈការចរចាលេខ............................ចុះថ្ងៃទី.......................................

- កំណត់ហេតុដោះស្រាយតាមរយៈការចរចាលេខ............................ចុះថ្ងៃទី.......................................

- សំណុំរឿងលេខ.......................ចុះថ្ងៃទី..................................................................................

-...........................................................................................................................................

-...........................................................................................................................................

-...........................................................................................................................................

**សមាសភាពនៃ គ.ជ.ក.ប.**

| | | | |
|---|---|---|---|
| ១. ឯកឧត្តម ប៉ាន សូរស័ក្តិ | ប្រធាន | ៧. ឯកឧត្តម អឿន បូរ៉ារ័ត្នន៍ | សមាជិក |
| ២. ឯកឧត្តម ម៉ក់ ពេជ្ជរិទ្ធ | អនុប្រធានអចិន្ត្រៃយ៍ | ៨. ឯកឧត្តម ចាន់ ចេស្តា | សមាជិក |
| ៣. ឯកឧត្តម មៀច សុផាន់ណា | អនុប្រធាន | ៩. ឯកឧត្តម ពេជ អង្គ | សមាជិក |
| ៤. ឯកឧត្តម ឆាន់ វឌ្ឍនៈ | អនុប្រធាន | ១០. ឯកឧត្តម គង់ ផល្លៈ | សមាជិក |
| ៥. លោកជំទាវ ពៅ វរលក្ស្មណ៍ | អនុប្រធាន | ១១. ឯកឧត្តម ផាន អូន | សមាជិកនិងជាលេខាធិការ |
| ៦. ឯកឧត្តម សន សោភ័ណ | អនុប្រធាន | ១២. លោក ហេង បូមករា | សមាជិក |

**អង្គហេតុ**

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

## យល់ឃើញថា

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

## សម្រេច

១..............................................................................................................................................................

២..............................................................................................................................................................

៣..............................................................................................................................................................

៤..............................................................................................................................................................

៥..............................................................................................................................................................

ថ្ងៃ..........................ខែ...............ឆ្នាំ................ព.ស.២៥៦.....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ខែ............ឆ្នាំ២០២.........

**ជ.គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

**ប្រធាន**